**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Jun-2013, 10:20
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺពីអំណាចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការបើកឡើងវិញនូវកិច្ចដំណើរការនីតិវិធីលើភស្តុតាងនៅក្នុងពេលណាមួយមុនពេលចេញ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASIINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele NUMBA

**ចម្លងជូន:**
សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សំណើ

១. អនុលោមតាមវិធាន១០៤ និង១០៥ នៃវិធានផ្ទៃក្នុង ("វិធាន")[1] សហព្រះរាជអាជ្ញាដាក់សំណើនេះ ("សំណើ") សុំឲ្យអង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") បំភ្លឺថា ខ្លួនមានអំណាចក្នុងការបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូង បើកសវនាការលើភ័ស្តុតាងសារជាថ្មីឡើងវិញ ក្នុងពេលណាមួយនៅក្រោយការបិទ រហូតដល់សាលក្រមស្តាពររបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ បានចេញ។

## II.ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចរបស់ខ្លួនស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី នៃសំណុំរឿង០០២[2] ("ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី") បន្ទាប់ពីមានមោឃភាពសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះ[3] ទៅលើសេចក្តីសម្រេចពីមុនរបស់អង្គជំនុំជម្រះសាលាដំបូង[4]។

៣. នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចមួយដែលមានចំណងជើងថា "សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំការបង្គាប់ជាបន្ទាន់ទៅអង្គជំនុំជម្រះសាលាដំបូង ឲ្យចេញសេចក្តីសម្រេចដែលមានសម្អាងហេតុ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២" ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី")។ នៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះនេះបានកត់សម្គាល់ថា សូម្បីតែដំណាក់កាលបង្ហាញភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ នៅមុនពេលផុតកំណត់កាលបរិច្ឆេទ សម្រាប់ចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ជាយថាហេតុនោះក៏ដោយ "ការធ្វើឲ្យប៉ះពាល់ដល់សិទ្ធិណាមួយដែលអាចកើតចេញពីកំហុសណាមួយនោះ *តម្រូវឲ្យមានការធ្វើអន្តរាគមន៍ និងពិនិត្យពិច័យលើបណ្តឹងសាទុក្ខ* តាមការចាំបាច់ ឬទៅតាមកាលៈទេសៈសមស្រប" ដែរ (សង្កត់ន័យត្រង់អក្សរទ្រេត)[5]។

---

[1] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (ច្បាប់វិសោធនកម្មលើកទី៨), វិសោធនកម្មនៅថ្ងៃទី៣ សីហា ២០១១ ("វិធាន")។

[2] **E284** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣។

[3] **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១, ៨ កុម្ភៈ ២០១៣។

[4] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរនៃវិធានផ្ទៃក្នុង, ២២ កញ្ញា ២០១១។

[5] **E163/5/1/13/3** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំការបង្គាប់ជាបន្ទាន់ទៅអង្គជំនុំជម្រះសាលាដំបូងឲ្យចេញសេចក្តីសម្រេចដែលមានសំអាងហេតុ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២", ៨ ឧសភា ២០១៣។

៤. នៅថ្ងៃទី១០ និងទី២៧ ខែឧសភា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញា[6] និង មេធាវីការពារក្តី នួន ជា[7] បានដាក់បណ្តឹងសាទុក្ខរៀងៗខ្លួន ជំទាស់នឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង។ ភាគីទាំងពីរបានស្នើសុំឲ្យមានការពន្លាតសំណុំរឿង 00២/0១។ បើមានដំណោះស្រាយណាមួយត្រូវបានអនុញ្ញាតឲ្យមានការពន្លាតសំណុំរឿងនេះ នោះកិច្ចដំណើរការនីតិវិធីដេញដោលលើភ័ស្តុតាងបន្ថែម នឹងមានលក្ខណៈជាការចាំបាច់។

៥. នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូង បានចេញអនុស្សរណៈមួយ ដែលបានអូសបន្ទាត់អំពី "សវនាការដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង 00២/0១"[8]។ អង្គជំនុំជម្រះសាលាដំបូង បានថ្លែងក្នុងអនុស្សរណៈនោះថា "ដើម្បីធានាបានការបញ្ចប់ទាន់ពេលវេលានៃសាលក្រមសម្រាប់សំណុំរឿង 00២/0១ និងអនុលោមតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងពុំពន្យារពេលការបញ្ចប់កិច្ចដំណើរការនីតិវិធីដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង 00២/0១ ដោយរង់ចាំសេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ជំទាស់នឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការជាថ្មីឡើយ (ឯកសារ E284) លើកលែងតែមានការបង្គាប់ដូច្នេះពីសំណាក់អង្គជំនុំជម្រះតុលាការកំពូល"[9]។ នៅទីនេះ ដោយអនុលោមតាមសិទ្ធិអំណាចដែលបានប្រគល់ឲ្យ ដូចដែលត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងដូច្នោះដែរ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូល ចេញដីកាបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូង ពន្យារពេលការបញ្ចប់កិច្ចដំណើរការនីតិវិធីដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង 00២/0១ រហូតដល់មានដំណោះស្រាយលើបណ្តឹងសាទុក្ខ ជំទាស់នឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការជាថ្មី នោះសិន។

## III. សំណោមជួសជុលដែលស្វែងរក

៦. ដើម្បីឲ្យមានភាពប្រាកដប្រជាផ្នែកច្បាប់ សហព្រះរាជអាជ្ញា សូមស្នើដល់អង្គជំនុំជម្រះតុលាការកំពូល សូមមេត្តាបញ្ជាក់ឲ្យច្បាស់ថា បើសិនជាសវនាការដេញដោលលើភ័ស្តុតាងត្រូវចប់នៅមុនពេលចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេច ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរដែលអង្គជំនុំជម្រះនេះ

[6] **E284/2/1** បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង 00២, ១០ ឧសភា ២០១៣។

[7] **E284/4/1** បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងទៅនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាលើសេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, ២៧ ឧសភា ២០១៣។

[8] **E288** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការជូនដំណឹងអំពីសវនាការ ដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង 00២/0១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៣, ២១ ឧសភា ២០១៣។

[9] **E288** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការជូនដំណឹងអំពីសវនាការ ដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង 00២/0១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៣, ២១ ឧសភា ២០១៣, កថាខណ្ឌ ១០។

មានសិទ្ធិអំណាចក្នុងការចេញដីកាសម្រេចបង្គាប់ឲ្យ អង្គជំនុំជម្រះសាលាដំបូងបើកធ្វើសវនាការដេញដោលលើភ័ស្តុតាងជាថ្មីឡើងវិញ ប្រសិនបើ អង្គជំនុំជម្រះនេះ សម្រេចថា ឲ្យពង្រីកវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ០០២/០១។ បន្ថែមពីលើនេះ សូមស្នើអង្គជំនុំជម្រះតុលាការកំពូលមេត្តាបញ្ជាក់ច្បាស់ថា ការបើកសវនាការដេញដោលលើភ័ស្តុតាងសារជាថ្មីឡើងវិញនេះ អាចត្រូវបង្គាប់ឲ្យធ្វើនៅពេលណាក៏បាន នៅមុនពេលអង្គជំនុំជម្រះសាលាដំបូង ចេញសាលក្រមស្តាពរ នៅក្នុងសំណុំរឿងលេខ ០០២/០១៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |